# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ១៥០ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៧

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសេវាគាំពារទីក្រុងស្អាត និងជំរុញការប្រឡងប្រណាំង នៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦១៤ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

# សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសេវាគាំពារទីក្រុងស្អាត និងជំរុញការប្រឡងប្រណាំង នៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅដូចខាងក្រោម៖

- ធានាប្រសិទ្ធភាពការងារ និងការទទួលខុសត្រូវរបស់នាយកដ្ឋានសេវាគាំពារទីក្រុងស្អាត និងជំរុញការប្រឡងប្រណាំងនៃក្រសួងទេសចរណ៍
- បង្កើត និងបង្កើនយន្តការនៃការគាំពារទីក្រុងស្អាត និងជំរុញចលនាប្រឡងប្រណាំងថ្នាក់ជាតិ និងថ្នាក់តំបន់អំពីអត្ថប្រយោជន៍នៃការប្រឡងប្រណាំង
- ធានានូវការគ្រប់គ្រងវិស័យទេសចរណ៍ដោយឈរលើគោលការណ៍និរន្តរភាព និងការទទួលខុសត្រូវ។

## ជំពូកទី ២
## តួនាទី និងភារកិច្ច

**ប្រការ ៣.-**

**នាយកដ្ឋានសេវាគាំពារទីក្រុងស្អាត និងជំរុញការប្រឡងប្រណាំង** ចំណុះអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងជាសេនាធិការឱ្យក្រសួងទេសចរណ៍ ទទួលបន្ទុកការងារគាំពារ និងជំរុញរាល់ចលនាប្រឡងប្រណាំងថ្នាក់ជាតិ អន្តរជាតិ តាមរយៈ ការពង្រឹងសមត្ថភាពដល់មន្ត្រីវាយតម្លៃទីក្រុងស្អាត ថ្នាក់រាជធានី ខេត្ត ការគ្រប់គ្រងលើនីតិវិធីពិនិត្យពាក្យស្នើសុំចូលរួមប្រឡងប្រណាំង ការចូលរួមបង្កើតនិងធ្វើបច្ចុប្បន្នកម្មបទដ្ឋានគតិយុត្តដូចជាស្តង់ដា ឬគោលការណ៍ណែនាំក្នុងការប្រឡងប្រណាំង ការផ្សព្វផ្សាយស្តង់ដា និងគោលការណ៍ណែនាំប្រឡងប្រណាំងដល់ប្រតិបត្តិករទេសចរណ៍ និងស្ថាប័នពាក់ព័ន្ធ សំដៅជំរុញ កែលម្អ និងរក្សាគុណភាពសេវាកម្មទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**នាយកដ្ឋានសេវាគាំពារទីក្រុងស្អាត និងជំរុញការប្រឡងប្រណាំង** មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវ កសាង និងធ្វើបច្ចុប្បន្នកម្មគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តនានា ឯកសារស្តង់ដាធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ បម្រើឱ្យចលនាប្រឡងប្រណាំងរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ និងស្តង់ដាបដិសណ្ឋារកិច្ចល្អ បម្រើឱ្យចលនាប្រឡងប្រណាំង "បដិសណ្ឋារកិច្ចល្អ"
- រៀបចំគម្រោងសហប្រតិបត្តិការជាមួយនឹងអង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធ ដើម្បីទ្រទ្រង់ដល់ចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ" ចលនាប្រឡងប្រណាំង "បដិសណ្ឋារកិច្ចល្អ" និងចលនាប្រឡងប្រណាំងរង្វាន់ធុរកិច្ចបៃតង ក្នុងវិស័យទេសចរណ៍
- រៀបចំគម្រោងគំរូនានាទ្រទ្រង់ដល់ចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"
- ជំរុញការចូលរួមពីសាធារណៈជន និងគ្រប់ភាគីពាក់ព័ន្ធក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត ចលនាប្រឡងប្រណាំង "បដិសណ្ឋារកិច្ចល្អ" និងចលនាប្រឡងប្រណាំងរង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍
- រៀបចំ និងដំណើរការមជ្ឈមណ្ឌលទ្រទ្រង់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍
- រៀបចំវគ្គបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់មន្ត្រីវាយតម្លៃទីក្រុងស្អាត មន្ត្រីក្រុមការងារវាយតម្លៃទីក្រុងស្អាតរាជធានី ខេត្ត
- បង្កើត គ្រប់គ្រង រចនា និងធ្វើបច្ចុប្បន្នកម្មគេហទំព័ររបស់ **គ.ជ.វ.ទ.** គេហទំព័រធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ និងគេហទំព័រ "បដិសណ្ឋារកិច្ចល្អ"
- រៀបចំពិនិត្យ និងចងក្រងគ្រប់ឯកសារផ្សព្វផ្សាយអំពីចលនាប្រឡងប្រណាំងទីក្រុងស្អាត អំពីសកម្មភាពរបស់ **គ.ជ.វ.ទ.** និងអំពីធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍
- សហការជាមួយស្ថាប័នរដ្ឋ ឯកជន អង្គការ សមាគមជាតិ និងអន្តរជាតិ វិទ្យាស្ថានស្រាវជ្រាវជាតិ និងអន្តរជាតិ បណ្តាញធុរកិច្ចបៃតង គ្រឹះស្ថានឧត្តមសិក្សានានា សំដៅពង្រឹង និងពង្រីកការងារស្រាវជ្រាវ និងការផ្សព្វផ្សាយ "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ" ឱ្យបានទូលំទូលាយ ព្រមទាំងជំរុញការអភិវឌ្ឍសមត្ថភាពផ្នែកធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ដល់គ្រប់ភាគីពាក់ព័ន្ធ

- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍។

**នាយកដ្ឋានសេវាគាំពារទីក្រុងស្អាត និងជំរុញការប្រឡងប្រណាំង ដឹកនាំដោយប្រធាន មួយ(០១)រូប និងអនុប្រធាន** មួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**ប្រការ ៤.-**

នាយកដ្ឋានសេវាគាំពារទីក្រុងស្អាត និងជំរុញការប្រឡងប្រណាំង មានការិយាល័យចំណុះចំនួន **០៥(ប្រាំ)** ដូចខាងក្រោម៖

១-ការិយាល័យជំរុញការប្រឡងប្រណាំងរង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍

២-ការិយាល័យជំរុញការប្រឡងប្រណាំង "បដិសណ្ឋារកិច្ចល្អ"

៣-ការិយាល័យជំរុញការប្រឡងប្រណាំង "បង្គន់សាធារណៈ"

៤-ការិយាល័យជំរុញការប្រឡងប្រណាំងកម្ពុជាស្អាត សាលាស្អាត និងផ្សារស្អាត

៥-ការិយាល័យផែនការ ស្រាវជ្រាវ បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពទ្រទ្រង់ចលនាប្រឡងប្រណាំង។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន **មួយ(០១)រូប** និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់នាយកដ្ឋានសេវាគាំពារទីក្រុងស្អាតនិងជំរុញការប្រឡងប្រណាំងជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី ៤
## តួនាទី និងភារកិច្ចរបស់ការិយាល័យ

**ប្រការ ៥.-**

ការិយាល័យនីមួយៗ មានតួនាទី និងភារកិច្ចដូចតទៅ៖

**១-ការិយាល័យជំរុញការប្រឡងប្រណាំងរង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍** មានតួនាទី និងភារកិច្ច៖

- រៀបចំបង្កើត និងធ្វើបច្ចុប្បន្នកម្មបទដ្ឋានគតិយុត្ត ស្តង់ដា គោលការណ៍ណែនាំ បទប្បញ្ញត្តិក្នុងការប្រឡងប្រណាំង
- តាមដាន និងត្រួតពិនិត្យការអនុវត្តរបស់បេក្ខភាពជ័យលាភីប្រឡងប្រណាំង
- សហការផ្សព្វផ្សាយអំពីការប្រឡងប្រណាំងរង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ ដល់ប្រតិបត្តិករទេសចរណ៍ និងស្ថាប័នពាក់ព័ន្ធ
- អនុវត្តនីតិវិធីពិនិត្យ ចងក្រង និងវាយតម្លៃបេក្ខភាពចូលរួមចលនាប្រឡងប្រណាំងរង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ និងរៀបចំរបាយការណ៍លទ្ធផលវាយតម្លៃជូនថ្នាក់ដឹកនាំ
- ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ដល់ទីតាំងជាក់ស្តែងរបស់បេក្ខភាពប្រឡងប្រណាំង
- រៀបចំ ចងក្រងវិភាគលើបញ្ហាប្រឈម និងដំណោះស្រាយក្នុងដំណើរការប្រឡងប្រណាំងរង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍
- រៀបចំចងក្រងបញ្ជីបេក្ខភាពជ័យលាភី និងធ្វើបច្ចុប្បន្នភាពលើគេហទំព័រធុរកិច្ចបៃតង
- ប្រមូល វិភាគ និងរក្សាទុករាល់ឯកសារ ទិន្នន័យដែលពាក់ព័ន្ធនឹងការប្រឡងប្រណាំង ដើម្បីចងក្រងជាសៀវភៅវឌ្ឍនភាព
- រៀបចំ និងដំណើរការមជ្ឈមណ្ឌលទ្រទ្រង់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍។

២-ការិយាល័យជំរុញការប្រឡងប្រណាំង"បដិសណ្ឋារកិច្ចល្អ" មានតួនាទី និងភារកិច្ចៈ

- រៀបចំបង្កើត និងធ្វើបច្ចុប្បន្នកម្មបទដ្ឋានគតិយុត្ត ស្តង់ដា គោលការណ៍ណែនាំ បទប្បញ្ញត្តិក្នុងការប្រឡងប្រណាំង
- តាមដាន និងត្រួតពិនិត្យការអនុវត្តរបស់បេក្ខភាពជ័យលាភីប្រឡងប្រណាំង
- សហការផ្សព្វផ្សាយអំពីការប្រឡងប្រណាំងបដិសណ្ឋារកិច្ចល្អដល់ក្រុង ខណ្ឌបេក្ខភាព ក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត បេក្ខភាពច្រកទ្វារអន្តរជាតិ និងប្រតិបត្តិករទេសចរណ៍
- អនុវត្តនីតិវិធីពិនិត្យ ចងក្រង និងវាយតម្លៃបេក្ខភាពចូលរួមចលនាប្រឡងប្រណាំងបដិសណ្ឋារកិច្ចល្អ និងរៀបចំរបាយការណ៍លទ្ធផលវាយតម្លៃជូនថ្នាក់ដឹកនាំ
- ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ដល់ទីតាំងជាក់ស្តែងរបស់បេក្ខភាពប្រឡងប្រណាំង
- រៀបចំ ចងក្រង វិភាគលើបញ្ហាប្រឈម និងដំណោះស្រាយក្នុងដំណើរការប្រឡងប្រណាំងបដិសណ្ឋារកិច្ចល្អ
- រៀបចំចងក្រងបញ្ជីបេក្ខភាពជ័យលាភី និងធ្វើបច្ចុប្បន្នភាពលើគេហទំព័របដិសណ្ឋារកិច្ចល្អ
- ប្រមូល វិភាគ និងរក្សាទុករាល់ឯកសារ ទិន្នន័យដែលពាក់ព័ន្ធនឹងការប្រឡងប្រណាំង ដើម្បីចងក្រង ជាសៀវភៅវឌ្ឍនភាព។

៣-ការិយាល័យជំរុញការប្រឡងប្រណាំង"បង្គន់សាធារណៈ" មានតួនាទី និងភារកិច្ចៈ

- រៀបចំបង្កើតនិងធ្វើបច្ចុប្បន្នកម្មបទដ្ឋានគតិយុត្តិ ស្តង់ដាគោលការណ៍ណែនាំបទប្បញ្ញត្តិប្រឡងប្រណាំង
- ផ្សព្វផ្សាយ និងជំរុញចលនាប្រឡងប្រណាំងបង្គន់សាធារណៈកម្ពុជា និងអាស៊ាន ដល់ក្រុង/ខណ្ឌបេក្ខភាពទាំងអស់
- រៀបចំបង្កើតយុទ្ធនាការ"បង្គន់សាធារណៈ១០០" នៅតាមក្រុង/ខណ្ឌបេក្ខភាពទាំងអស់ និងយុទ្ធនាការបង្គន់សាធារណៈផ្សេងៗទៀត
- សហការរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាស្តីពីការជម្រុញចលនាប្រឡងប្រណាំងបង្គន់សាធារណៈកម្ពុជា និងអាស៊ាន
- អនុវត្តនីតិវិធីពិនិត្យ ចងក្រង និងវាយតម្លៃបេក្ខភាពចូលរួមចលនាប្រឡងប្រណាំង និងរៀបចំរបាយការណ៍លទ្ធផលវាយតម្លៃជូនថ្នាក់ដឹកនាំ
- ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ដល់ទីតាំងជាក់ស្តែងរបស់បេក្ខភាពប្រឡងប្រណាំង
- រៀបចំ ចងក្រង វិភាគលើបញ្ហាប្រឈម និងដំណោះស្រាយក្នុងដំណើរការប្រឡងប្រណាំង
- រៀបចំចងក្រងបញ្ជីបេក្ខភាពជ័យលាភី និងធ្វើបច្ចុប្បន្នភាពលើគេហទំព័រ
- ប្រមូល វិភាគ និងរក្សាទុករាល់ឯកសារ ទិន្នន័យដែលពាក់ព័ន្ធនឹងការប្រឡងប្រណាំង ដើម្បីចងក្រងជាសៀវភៅវឌ្ឍនភាព។

៤-ការិយាល័យជំរុញការប្រឡងប្រណាំងកម្ពុជាស្អាត សាលាស្អាត និងផ្សារស្អាត មានតួនាទី និងភារកិច្ចៈ

- រៀបចំបង្កើត និងធ្វើបច្ចុប្បន្នកម្មបទដ្ឋានគតិយុត្ត ស្តង់ដា គោលការណ៍ណែនាំ បទប្បញ្ញត្តិក្នុងការប្រឡងប្រណាំង
- សហការផ្សព្វផ្សាយអំពីការប្រឡងប្រណាំងកម្ពុជាស្អាត សាលាស្អាត និងផ្សារស្អាត
- អនុវត្តនីតិវិធីពិនិត្យ ចងក្រង និងវាយតម្លៃបេក្ខភាពចូលរួមចលនាប្រឡងប្រណាំងកម្ពុជាស្អាត សាលាស្អាត ផ្សារស្អាត និងរៀបចំរបាយការណ៍លទ្ធផលវាយតម្លៃជូនថ្នាក់ដឹកនាំ
- ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ដល់ទីតាំងជាក់ស្តែងរបស់បេក្ខភាពប្រឡងប្រណាំង
- រៀបចំ ចងក្រង វិភាគលើបញ្ហាប្រឈម និងដំណោះស្រាយក្នុងដំណើរការប្រឡងប្រណាំង
- រៀបចំចងក្រងបញ្ជីបេក្ខភាពជ័យលាភី និងធ្វើបច្ចុប្បន្នភាពលើគេហទំព័រកម្ពុជាស្អាត

- ប្រមូល វិភាគ និងរក្សាទុករាល់ឯកសារ ទិន្នន័យដែលពាក់ព័ន្ធនឹងការប្រឡងប្រណាំង ដើម្បីចងក្រងជាសៀវភៅវឌ្ឍនភាព
- ជំរុញការចូលរួមសកម្មភាពទីក្រុងស្អាតតាមរយៈការបង្កើតសកម្មជនទីក្រុងស្អាត-អេកូក្លឹប នៅតាមគ្រឹះស្ថានសិក្សា កន្លែងធ្វើការ វត្តអារ៉ាម សហគមន៍ និងទីប្រជុំជននានា។

**៥-ការិយាល័យផែនការ ស្រាវជ្រាវ បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពទ្រទ្រង់ចលនាប្រឡងប្រណាំង** មានតួនាទី និងភារកិច្ចៈ

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការនិងកម្មវិធីអភិវឌ្ឍន៍នានាដែលទ្រទ្រង់ចលនាប្រឡងប្រណាំង
- រៀបចំគម្រោងអភិវឌ្ឍន៍នានាដែលទ្រទ្រង់ដល់ចលនាប្រឡងប្រណាំង
- អង្កេត និងវាយតម្លៃគម្រោងអភិវឌ្ឍន៍ការងារប្រឡងប្រណាំង
- សិក្សា ស្រាវជ្រាវ លើកគម្រោងផែនការ និងរៀបចំកម្មវិធីបណ្តុះបណ្តាល និងពង្រឹងសមត្ថភាព មន្ត្រីនាយកដ្ឋាន និងក្រុមការងារវាយតម្លៃទីក្រុងស្អាតរាជធានី ខេត្ត
- សិក្សា ស្រាវជ្រាវឯកសារ ច្បាប់ជាតិ និងអន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធចលនាប្រឡងប្រណាំងដើម្បីធ្វើបច្ចុប្បន្នភាព
- រៀបចំ ប្រមូល ចងក្រង និងគ្រប់គ្រងលិខិតបទដ្ឋានគតិយុត្តនានាទាក់ទងនឹងចលនាប្រឡងប្រណាំង។

**ប្រការ ៦.-**

ការិយាល័យនីមួយៗ ចំណុះឱ្យនាយកដ្ឋានសេវាគាំពារទីក្រុងស្អាត និងជំរុញការប្រឡងប្រណាំង មានតួនាទី និងភារកិច្ចៈ

- ធ្វើកំណត់ហេតុប្រជុំដែលពាក់ព័ន្ធនឹងការងារទទួលខុសត្រូវរបស់ខ្លួន
- រៀបចំផែនការសកម្មភាពការងារ និងថវិកាចំណាយ ផ្សេងៗ និងប្រចាំឆ្នាំជូនប្រធាននាយកដ្ឋាន
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនប្រធាននាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន នាយកវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានធនធានមនុស្ស ប្រធាននាយកដ្ឋានសេវាគាំពារទីក្រុងស្អាត និងជំរុញការប្រឡងប្រណាំង ប្រធានគ្រប់អង្គភាពចំណុះក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ